ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ ៤២៨ សរា៣ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥

**ជម្រាបជូន**

**លោកស្រី សារ៉ា សីគស៍ ប្រធានប្រចាំប្រទេស នៃអង្គការ Pact**

**<u>កម្មវត្ថុ៖</u>** អំពីសំណើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមរបស់អង្គការ Pact នៅក្នុងស្រុកគោលដៅចំនួន៥ ឃុំចំនួន៤៣ នៃខេត្តកំពង់ចាម បាត់ដំបង ពោធិ៍សាត់ និងខេត្តមណ្ឌលគីរី ។

**<u>យោង៖</u>** -លិខិតលេខ២៨៤/២០១៥/ផេក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ស្នើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម របស់អង្គការ Pact ។
-ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកស្រីប្រធានជ្រាបថា៖ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគាំទ្រ និងសហការជាមួយអង្គការ Pact លើការអនុវត្តផែនការសកម្មភាពផ្នែកតម្រូវការ ក្នុងផែនការយុទ្ធសាស្ត្រស្តីពី ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលផ្តោតសំខាន់លើសេវាមូលដ្ឋានទាំងបីរួមមាន៖ ការផ្តល់សេវារបស់រដ្ឋបាលឃុំ សេវាមណ្ឌលសុខភាព និងសាលាបឋមសិក្សា នៅក្នុងឃុំចំនួន៤៣ ស្រុកគោលដៅចំនួន៥ នៃខេត្តចំនួន៤ គឺខេត្តកំពង់ចាម បាត់ដំបង ពោធិ៍សាត់ និងខេត្តមណ្ឌលគីរី សម្រាប់ឆ្នាំ២០១៥ នេះ ដូចមានលម្អិតក្នុងតារាងភ្ជាប់ជូនមកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកស្រីប្រធាន មេត្តាចាត់ចែងអនុវត្ត តាមនីតិវិធីប្រើប្រាស់ឧបករណ៍គណនេយ្យភាពសង្គម ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានដាក់ឲ្យអនុវត្ត និងត្រូវសហការជាមួយរដ្ឋបាលខេត្ត ស្រុក ឃុំ និងអ្នកពាក់ព័ន្ធ នៅតាមតំបន់គោលដៅដែលបានកំណត់ ឲ្យទទួលបានលទ្ធផលល្អប្រសើរ។

សូមលោកស្រីប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**អនុប្រធាន**

**ចាន់ ចរិន**

**<u>ចម្លងជូន៖</u>**
- រដ្ឋបាលខេត្តកំពង់ចាម បាត់ដំបង ពោធិ៍សាត់ និងខេត្តមណ្ឌលគីរី
- រដ្ឋបាលស្រុក ឃុំ គោលដៅ
"ដើម្បីសហការអនុវត្ត"